**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
លេខ.....................

# សេចក្តីប្រកាសព័ត៌មាន
# អ្នកនាំពាក្យក្រសួងការពារជាតិ

យោងតាមកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសហប្រជាជាតិ (អ.ស.ប) ក្រសួងការពារជាតិ នឹងបញ្ជូនកងវិស្វកម្មលេខ៥៩៤ ចំនួន២១៦នាក់ ក្នុងនោះ រួមទាំងនារី ១០នាក់ ទៅចូលរួមបេសកកម្មរក្សាសន្តិភាពអ.ស.ប នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ដែលពិធីជូនដំណើរនឹងប្រព្រឹត្ត ទៅក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ុល សារឿន ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស នៅវេលាម៉ោង ៨:០០នាទី ព្រឹកថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅមូលដ្ឋានទ័ពអាកាសពោធិ៍ចិនតុង រាជធានីភ្នំពេញ។

ដោយឡែក កម្មវិធីមាតុភូមិនិវត្តន៍នៃកងវិស្វកម្មលេខ៩៥៤ ចំនួន២១៦នាក់ ក្នុងនោះរួមមាននារីចំនួន ១៤នាក់ពីសាធាណរដ្ឋអាហ្វ្រិកកណ្តាល និងកងរាជអាវុធហត្ថ លេខ៦១៨ ចំនួន៧៣នាក់ រួមទាំង នារី០៩នាក់ ពីសាធារណរដ្ឋស៊ូដង់ខាងត្បូង នឹងត្រូវបានរៀបចំឡើង ក្រោមអធិបតីភាព សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅវេលាម៉ោង ០៣:៣០នាទី រសៀលថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅមូលដ្ឋានទ័ពអាកាសពោធិចិនតុង រាជធានីភ្នំពេញ ។

កងវិស្វកម្ម លេខ៥៩៤ គឺជាកងវិស្វកម្មលើកទី៥ហើយ ដែលត្រូវបញ្ជូន ទៅចូលរួម បេសកកម្មរក្សាសន្តិភាពអ.ស.ប នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ហើយកងនេះ នឹងត្រូវទៅប្តូរវេនជំនួសកងវិស្វកម្មលេខ ៩៥៤ ដែលបានសម្រេចភារកិច្ចដោយជោគជ័យ ក្នុងបេសកកម្មរក្សាសន្តិភាពអ.ស.ប អាណត្តិ១ឆ្នាំរបស់ខ្លួន នៅសាធាណរដ្ឋអាហ្វ្រិកកណ្តាល៕

ថ្ងៃពុធ ៧រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨